# ភ្នំពេញ – សៀមរាប (៤ថ្ងៃ៣យប់)

## ថ្ងៃទី១ : ភ្នំពេញ_សៀមរាប_អង្គរវត្ត (អាហារ ២ពេល)



ធ្វើដំណើរពីភ្នំពេញឆ្ពោះទៅខេត្តសៀមរាបតាមផ្លូវជាតិលេខ៦។គយគន់ទេសភាពព្រៃព្រឹក្សា ខៀវស្រងាត់និងទទួលទានអាហារថ្ងៃនៅទីរួមខេត្តរួចបន្តដំណើរទៅកំសាន្តនេ ។ប្រាសាទអង្គរវត្តដែលជាប្រាសាទមួយកសាងឡើងនៅដើមសតវត្សទី១២ក្នុងសម័យអង្គរដែលមានចំលាក់ក្បូរក្បាច់រចនារស់រវើកដ៏ល្អវិចិត្រល្បីល្បាញគ្មានគូរប្រៀបប្រកួតបាននូវស្នាដៃដ៏ប៉ិនប្រសព្វរបស់បុព្វបុរសខ្មែរកាលពីសម័យមហានគរដ៏រុងរឿងនៃអាណាចក្រខ្មែរ បន្ទាប់មកបន្តដំណើរទៅទស្សនាប្រាសាទតាព្រហ្មត្រលប់មកប្រាសាទភ្នំបាក់ខែង និងគយគន់ទេសភាពនៃ ព្រះអាទិត្យលិចដ៏ស្រស់ត្រកាលនៅលើកំពូលភ្នំ។ អាហារពេលល្ងាចយ៉ាងឆ្ងាញ់ពិសេសជាប់ចិត្ត ហើយជូនទៅសណ្ឋាគារ។

## ថ្ងៃទី២ : សៀមរាប_ភូមិវប្បធម៌_អង្គរធំ (អាហារ ៣ពេល)



អាហារពេលព្រឹករួចជូនទៅទស្សនារមណីយដ្ឋានអង្គធំ ដែលសំបូរទៅដោយប្រាសាទល្បីៗជាច្រើនជាពិសេសប្រាសាទបាយ័នប្រាសាទបាពួនភិមានអាកាសដែលជាប្រាសាទដ៏អស្ចារ្យ បន្ទាប់ពីប្រាសាទអង្គរវត្ត។ អាហារថ្ងៃត្រង់រួចបន្តដំណើរទៅកំសាន្តនៅភូមិវប្បធម៌ ដែលជារមណីយដ្ឋានកៃច្នៃមួយដែលមានការទាក់ទាញពីភ្ញៀវជាតិនិងអន្តរជាតិហើយទៅទិញឥវ៉ាន់វត្ថុអនុស្សាវរីយ៍នៅផ្សារចាស់។ អាហារពេលល្ងាច រួចជូនត្រលប់ទៅសណ្ឋាគារ។

## ថ្ងៃទី៣ : សៀមរាប_ភ្នំគូលែន_ប្រាសាទតាកែវ (អាហារ ៣ពេល)



អាហារពេលព្រឹកបន្តដំណើរទៅកំសាន្តនៅភ្នំគូលែនរួចបន្តដំណើរទៅកំសាន្តនៅប្រាសាទក្រវាន់ ស្រះស្រង់ ប្រាសាទបន្ទាយក្តី ប្រាសាទតាកែវ ប្រាសាទទេពប្រណម។អាហារពេលល្ងាចប៊ូហ្វេត្រលប់ទៅសណ្ឋាគារ។

## ថ្ងៃទី៤ : សៀមរាប_បន្ទាយស្រី_ភ្នំពេញ (អាហារ ២ពេល)



អាហារពេលព្រឹកហើយធ្វើដំណើរទៅប្រាសាទបន្ទាយស្រីដែលជា ប្រាសាទមួយដែលមានក្បាច់យ៉ាងល្អជាងគេនិងបន្ត ទស្សនាប្រាសាទបន្ទាយសំរែ។ អាហារថ្ងៃត្រង់ រួចបន្តត្រលប់មកភ្នំពេញវិញ ប្រកបដោយស្នាមញញឹមនិងសុវត្ថិភាព។

ដំណើរកំសាន្តរួមមាន :

☞មធ្យោបាយធ្វើដំណើរដោយរថយន្តទេសចរណ៍ទំនើបមានម៉ាស៊ីនត្រជាក់

☞បន្ទប់ស្នាក់នៅរួមសំរាប់គ្នា ២នាក់ក្នុងមួយបន្ទប់ ៕ សណ្ឋាគារផ្កាយ

☞សំបុត្រចូលទស្សនា

☞អាហារតាមកម្មវិធី១ថ្ងៃ៣ពេលនិងទឹកបរិសុទ្ធ

☞សេវាកម្មពីមគ្គុទ្ទេសក៍ទេសចរណ៍

☞វត្ថុអនុស្សាវរីយ៍ពី ក្រុមហ៊ុន អេស៊ីអាអិចផ្លរ៉ឺទេសចរណ

បញ្ជាក់:

☞ចេញដំណើររាល់ថ្ងៃសុក្រ និងថ្ងៃបុណ្យជាតិផ្សេង និងទៅតាមតំរូវការចំពោះក្រុមដែលមានគ្នា ចាប់ពី១០នាក់ឡើង។

☞ក្មេងក្រោមអាយុ១២ឆ្នាំ ស្នាក់នៅជាមួយឪពុកម្តាយតំលៃ ៧៥% នៃមនុស្សពេញវ័យ

☞សំរាប់ការស្នាក់នៅបន្ទប់មួយម្នាក់ឯងត្រូវបង់បន្ថែម ៣០ ដុល្លាអាមេរិក

ព័ត៌មានលំអិតសូមអញ្ជើញទំនាក់ទំនង

ទូរស័ព្ទលេខ: ០២៣ ២១៨ ៦០៩

អ៊ីមែល: book@asiaexplorertravel.com